**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

CAMFEBA
IN
No. 029
Date: 26/03/21
From: MoLVT
Time:
Received by: Sophea
Att:

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ៣៤០/២១ ក.ប/ខ.ល

## ជម្រាបជូន

## លោកឧកញ៉ា លោកជំទាវឧកញ៉ា លោក លោកស្រី ម្ចាស់ ឬនាយករោងចក្រ ក្រៅពីវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូប

**កម្មវត្ថុ** ៖ សំណើសុំផ្តល់បញ្ជីឈ្មោះកម្មករនិយោជិតស្ម័គ្រចិត្តចាក់វ៉ាក់សាំងកូវីដ-១៩។

**យោង** ៖ សេចក្តីសម្រេចលេខ០២៨/២១ក.ប/ស.ស.រ.ខ.ល ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ ស្តីពីការបង្កើតអនុគណៈកម្មការចំពោះកិច្ចសម្រាប់ចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ កម្មករនិយោជិតតាមរោងចក្រ សហគ្រាស និងកម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកឧកញ៉ា លោកជំទាវឧកញ៉ា លោក លោកស្រី** ជ្រាបថា ដើម្បីការពារសុខភាពជូនបងប្អូនកម្មករនិយោជិតនៅតាមរោងចក្រ សហគ្រាស ពីការឆ្លងជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលនឹងរៀបចំយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ដោយឥតគិតថ្លៃជូននាពេលឆាប់ៗដ៏ខ្លីខាងមុខនេះ។ ក្នុងន័យនេះ ដើម្បីឱ្យដំណើរការចាក់វ៉ាក់សាំងកូវីដ-១៩ ប្រព្រឹត្តទៅបានដោយរលូននិងមានប្រសិទ្ធភាព និងឈរលើគោលការណ៍ស្ម័គ្រចិត្ត **លោកឧកញ៉ា លោកជំទាវឧកញ៉ា លោក លោកស្រី** ត្រូវផ្តល់បញ្ជីឈ្មោះកម្មករនិយោជិតស្ម័គ្រចិត្តចាក់វ៉ាក់សាំង (ដូចមានក្នុងឧបសម្ព័ន្ធ) ជា Excel File និងស្កេនបញ្ជីឈ្មោះដែលមានបោះត្រារោងចក្រ សហគ្រាស នៅគ្រប់ទំព័រ មកអ៊ីមែល: covid19.vaccination@mlvt.gov.kh ដោយសរសេរនៅក្នុងកម្មវត្ថុអ៊ីមែលថា Covid19_Vaccination Others_...... (ឈ្មោះរោងចក្រ សហគ្រាសជាអក្សរឡាតាំង) ...... យ៉ាងយូរត្រឹមថ្ងៃទី៣ ខែមេសា ឆ្នាំ២០២១។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនឹងធ្វើការជូនដំណឹងអំពីកាលបរិច្ឆេទ និងទីតាំងនៃការចាក់វ៉ាក់សាំងកូវីដ-១៩ បន្ទាប់ពីទទួលបានបញ្ជីឈ្មោះកម្មករនិយោជិតស្ម័គ្រចិត្តចាក់វ៉ាក់សាំង។ សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងលេខទូរស័ព្ទ **០៩២ ២០៨ ៧៩៧ និង ០១១ ៤៥៦ ៤៥៧**។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកឧកញ៉ា លោកជំទាវឧកញ៉ា លោក លោកស្រី** ជាម្ចាស់ ឬនាយករោងចក្រ សហគ្រាស អនុវត្តតាមខ្លឹមសារនៃលិខិតនេះឱ្យបានត្រឹមត្រូវ។

សូម **លោកឧកញ៉ា លោកជំទាវឧកញ៉ា លោក លោកស្រី** ទទួលនូវការរាប់អានពីខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃ ២៥ ខែ មីនា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន**:

- សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មនៅកម្ពុជា